ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ៥៥៧
ថ្ងៃទី ២៤-០២-១៧
បញ្ជូន..........

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ១៦៥ សជណ.កស

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍អនុញ្ញាតដាក់សមត្ថកិច្ចពាក់ព័ន្ធ ចូលរួមត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យ លើផលិតផលកសិកម្ម ជលផល និងសត្វនៅតាមច្រកនាំចេញ នាំចូល។

**យោង ៖** -លិខិតលេខ ១៣៧៥ កសក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

-ចំណារ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាល អនុញ្ញាតជាគោលការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ថែមសមត្ថកិច្ចជំនាញពាក់ព័ន្ធមួយចំនួនទៀតក្រោមឱវាទក្រសួង រួមមាន កសិកម្ម ជលផល និងបសុព្យាបាល ដើម្បីចូលរួមត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យតាមសមត្ថកិច្ចរៀងៗខ្លួននៅប៉ុស្តិ៍ត្រួតពិនិត្យមាត់ច្រកនាំចេញ នាំចូលបន្ថែមទៀត ដោយសហការជាមួយសមត្ថកិច្ចគយ និងរដ្ឋាករ ប៉ុន្តែនៅក្រោមច្រកចេញចូលតែមួយ និងជៀសវាងច្រកច្រើននិងការយឺតយ៉ាវ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**រដ្ឋមន្ត្រីស្តីទី**

**ប៊ិន ឈិន**

**ចម្លងជូន:**
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- -រដ្ឋបាលជលផល
- -អគ្គនាយកដ្ឋានកសិកម្ម
- -អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- -ឯកសារ-កាលប្បវត្តិ

លេខ ០៤១ ចល.កសក

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើមលិខិតលេខ១៦៥ សជណ.កស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងបញ្ជូនមកៈ

-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជូនជ្រាប"

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជ្រាប និងមុខការ"

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

"ដើម្បីផ្សព្វផ្សាយ"

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៧

**ត.ប រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គលេខាធិការរង**

**ចាន់ ហោង**